# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/៣៤៩

## ស្តីពី

## ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ

### យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ១៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

ROYAUME DU CAMBODGE

បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត **ឧត្តមក្រុមប្រឹក្សាជាតិអប់រំ** ជាស្ថាប័នថ្នាក់ជាតិទទួលខុសត្រូវ នយោបាយអប់រំចំពោះមុខរាជរដ្ឋាភិបាល ដែលសរសេរជាអក្សរកាត់ថា**ឧ.ក.ជ.អ.** ។

## ជំពូកទី២

## សមាសភាព

**មាត្រា ២.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| - ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារអប់រំ | អនុប្រធាន |
| - ឥស្សរជនមួយរូប | អនុប្រធាន |
| - រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | មួយរូបជាសមាជិក |
| - ប្រធាន ឬ អនុប្រធាននៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល | មួយរូបជាសមាជិក |
| - ប្រធាន ឬ អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំ | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងផែនការ | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | មួយរូបជាសមាជិក |
| - រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងធម្មការ និងសាសនា | មួយរូបជាសមាជិក |

ROYAUME DU CAMBODGE

- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការនៃក្រសួងទេសចរណ៍ មួយរូបជាសមាជិក
- ឥស្សរជន ដែលមានបទពិសោធខាងអប់រំ នយោបាយ សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ មួយចំនួនជាសមាជិក

## ជំពូកទី ៣
## តួនាទី និង ភារកិច្ច

**មាត្រា ៣.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្រ រយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ច របស់ប្រទេសជាតិជូនរាជរដ្ឋាភិបាល
- វាយតម្លៃការងារដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមកាលកំណត់ជូនរាជរដ្ឋាភិបាល
- កៀរគរគ្រប់ធនធាន ដើម្បីបម្រើបុព្វហេតុអប់រំ ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៩*

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

នស.រកត.០៣០៩.៣៥២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ : ៣៧០ ច.ល

ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មេសា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ាប់ ... ខិនកេន